# សេចក្តីថ្លែងការណ៍រួមស្តីពីការបំភិតបំភ័យពីរាជរដ្ឋាភិបាល និងការផ្សព្វផ្សាយរបស់ទូរទស្សន៍

យើងខ្ញុំជាអង្គការសង្គមស៊ីវិល ដូចមាននៅក្នុងបញ្ជីខាងលើនេះ [គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ អង្គការលីកាដូ និងអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា] មានការព្រួយបារម្ភយ៉ាងខ្លាំងទាក់ទងទៅនឹងបរិយាកាស ការបំភិតបំភ័យពីរាជរដ្ឋាភិបាល និងការជ្រៀតជ្រែកនៅក្នុងពេលបោះឆ្នោត។ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ រាជរដ្ឋាភិបាលបានចេញសេចក្តីថ្លែងការណ៍មួយ តាមចាប់អ្នកក្លែងការបន្លំលិខិតនៃការស្ទាបស្ទង់មតិអំពីនិន្នាការនៃការគាំទ្រគណបក្សនយោបាយរបស់អង្គការ IRI និងមានការផ្សព្វផ្សាយយ៉ាងខ្លាំងពីទូរទស្សន៍។

អង្គការសង្គមស៊ីវិលយល់ឃើញថា ៖

១. ការអំពាវនាវអោយសមត្ថកិច្ចតាមចាប់ជនដែលជាអ្នកក្លែងឯកសារនេះ គឺផ្ទុយទាំងស្រុងទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍នៃនីតិរដ្ឋ ដោយសារតែឯកសារដែលត្រូវបានក្លែងនោះមិនមែនជាឯកសារសាធារណៈ ម្យ៉ាងវិញទៀត អំពើនេះ គឺទាក់ទងតែទៅនឹងភាគី ឫតំណាងនៃអង្គការ IRI តែប៉ុណ្ណោះ ប្រសិនបើ IRI ឫតំណាងបានដាក់ពាក្យបណ្តឹងទៅតុលាការមានសមត្ថកិច្ចអំពីការក្លែងបន្លំឯកសាររបស់ IRI។ ប៉ុន្តែ តំណាងនៃអង្គការ IRI បានបញ្ជាក់ហើយថា IRI មិនបានដាក់ពាក្យបណ្តឹងប្តឹងទៅបុគ្គលណាម្នាក់ឡើយ។

២. សេចក្តីថ្លែងការណ៍ ការផ្សព្វផ្សាយរបស់ទូរទស្សន៍អំពីសេចក្តីថ្លែងការណ៍អោយមានការតាមចាប់ខ្លួននោះមានការភិតភ័យពីប្រជាពលរដ្ឋ និងអាចធ្វើអោយបរិយាកាសនៅក្នុងពេលឃោសនាបោះឆ្នោតនេះមានលក្ខណៈអាប់អួ។ ជាក់ស្តែងធ្វើអោយមានការឃាត់ខ្លួន និងសួរចម្លើយដល់សកម្មជននៃគណបក្សនយោបាយពីរនាក់ ដែលរូបភាពនេះ គឺជាការបភិតបំភយ័ បើទោះបីជាសកម្មជនទាំងពីរនាក់នេះត្រូវបានគេដោះលែងវិញ។ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិនៅក្នុងការបញ្ចេញមតិ យោបល់ ក្នុងការប៉ាន់ស្មាន ការទស្សន៍ទាយអំពីលទ្ធផលនៃការបោះឆ្នោត និងការស្ទង់មតិ ឫការបកប្រែលទ្ធផលទៅតាមការយល់ឃើញ។ ការណ៍នេះ និងការយល់ដឹងរបស់ខ្លួន មិនមានអ្វីដែលអាចធ្វើអោយប៉ះពាល់ដល់ដំណើរការបោះឆ្នោតដោយសេរី និងត្រឹមត្រូវទេ។

៣. សូមអំពាវនាវដល់រាជរដ្ឋាភិបាល មេត្តាពិចារណាឡើងវិញ និងធ្វើការលប់ចោល ឬ/និងដកសេចក្តីថ្លែងការណ៍នោះចេញវិញ ហើយទូរទស្សន៍បញ្ឈប់ការផ្សាយសេចក្តីថ្លែងការណ៍នេះ ដើម្បីអោយដំណើរការឃោសនាបោះឆ្នោតប្រព្រឹត្តទៅដោយសេរី។

យើងខ្ញុំជាអង្គការសង្គមស៊ីវិល សង្ឃឹម និងជឿជាក់ថា រដ្ឋាភិបាលនឹងបង្ហាញអំពីតួនាទីឯករាជ្យពីគណបក្សនយោបាយ និងមិនជ្រៀតជ្រែកក្នុងដំណើរការកំឡុងពេលឃោសនាបោះឆ្នោតដើម្បីធានាថាការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌៕